វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការវិនិយោគលើការផលិតទំនិញទាក់ទងនឹងការធ្វើដំណើរមានការកើនឡើង ខណៈពេលក្រុមហ៊ុនផលិតមួយចំនួនបានចាកចេញពីប្រទេសចិន
- ធនាគារជាតិវៀតណាមសហការជាមួយធនាគារពាណិជ្ជ ដើម្បីធានាថាការផ្តល់ហិរញ្ញប្បទានលើវិស័យស្រូវអង្ករមានភាពគ្រប់គ្រាន់
- សញ្ញាបណ្ណរបស់អាមេរិច (US bond) ធ្លាក់ចុះ ដោយសារតែភាពមិនច្បាស់លាស់នៃពាណិជ្ជកម្ម

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះ- បណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការវិនិយោគលើការផលិតទំនិញទាក់ទងនឹងការធ្វើដំណើរមានការកើនឡើងខណៈពេលក្រុមហ៊ុនផលិតមួយចំនួនបានចាកចេញពីប្រទេសចិន

យោងតាមតួលេខដែលចេញផ្សាយដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានឱ្យដឹងថា ការវិនិយោគលើការផលិតទំនិញទាក់ទងនឹងការធ្វើដំណើរបានកើនឡើង នៅដើមឆ្នាំ២០១៩។ CDC បានអនុម័តគម្រោងវិនិយោគចំនួន ៤៥ នៅក្នុងខែមករា កុម្ភៈ និងនៅក្នុងសប្តាហ៍ទី១ នៃខែមីនា ដែលក្នុងនោះស្ទើតែពាក់កណ្តាលនៃចំនួនគម្រោងគឺជាគម្រោងលើការផលិតទំនិញសម្រាប់ការធ្វើដំណើរ។ គម្រោងវិនិយោគចំនួន ២១ ដែលមានទឹកប្រាក់ប្រមាណ ១០០លានដុល្លារ ត្រូវបានគេរំពឹងថានឹងបង្កើតការងារចំនួន ៣១ ៩៥១ ដល់ប្រជាជនកម្ពុជា។ កំណើននេះកើតឡើងដោយសារក្រុមហ៊ុនផលិតមួយចំនួនបានចាកចេញពីប្រទេសចិន ដើម្បីស្វែងរកទីតាំងនៅប្រទេសផ្សេងទៀតដែលមានតម្លៃពលកម្មទាប និងដើម្បីចៀសផុតពីការយកពន្ធដែលអាមេរិកបានដាក់ទៅលើការនាំចេញរបស់ប្រទេសចិន។ វិនិយោគិនកំពុងសម្លឹងមើលប្រទេសកម្ពុជាជាគោលដៅដៅវិនិយោគក្នុងការទាក់ទាញពាណិជ្ជកម្ម ដោយសារប្រទេសកម្ពុជាទទួលបាននូវប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្មពីអាមេរិក (General System of Preference)។

### តារាងប្រចាំសប្តាហ៍៖ចំនួនកុងតឺន័រឆ្លងកាត់ខេត្តព្រះសីហនុ

យោងតាមព្រឹត្តិបត្ររបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុចំនួនកុងតឺន័រដែលបានឆ្លងកាត់ខេត្តព្រះសីហនុ បានកើនឡើងជិតពីរដងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ គឺចាប់ពី ២៨៦ ៤៥០ ធីអ៊ីយូ

(១ TEU =២០ហ្វីត) ក្នុងឆ្នាំ២០១៣ ដល់ ៤៥៩ ៨៣៩ ធីអ៊ីយូ ក្នុងឆ្នាំ២០១៨។




ប្រភព៖ ព្រឹត្តិបត្រកំពង់ផែស្វយ័តក្រុងព្រះសីហនុរបស់ម្ពុជា, ឆ្នាំ២០១៨

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មផ្សេងទៀត

ធនាគារជាតិវៀតណាមសហការជាមួយធនាគារពាណិជ្ជ ដើម្បីធានាថា ការផ្តល់ហិរញ្ញប្បទានលើវិស័យស្រូវអង្ករមានភាពគ្រប់គ្រាន់អគ្គទេសាភិបាលធនាគារជាតិរបស់ប្រទេសវៀតណាម បានជំរុញអោយធនាគារពាណិជ្ជនៅក្នុងប្រទេសវៀតណាមសម្រាប់ការផ្តល់កម្ចី អោយទាន់ពេលវេលា ក្នុងអត្រាការប្រាក់សមរម្យដល់សហគ្រាសអង្ករ ជាពិសេសសហគ្រាសនាំចេញអង្ករ ដើម្បីអោយពួកគេមានលទ្ធភាពទិញស្រូវពីកសិករវៀតណាមនៅឆ្នាំនេះ។ ក្រោមការណែនាំរបស់ធនាគារជាតិ ធនាគារពាណិជ្ជ បានប្តេជ្ញាផ្តល់ប្រាក់កម្ចី ដែលមានតម្លៃជាសាច់ប្រាក់ចំនួន ៣៨៨ លានដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ប្រចាំឆ្នាំ ៦% ដើម្បីជួយដល់ក្រុមហ៊ុនអង្ករទទួលបានដើមទុនសម្រាប់ដំណើរការផលិត ការទិញ ការកែច្នៃ និងការប្រើប្រាស់អង្ករ។

កិច្ចសហប្រតិបត្តិការរបស់ធនាគារពាណិជ្ជក្នុងការផ្តល់ឥណទានដល់ឧស្សាហកម្មអង្ករដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម ព្រោះវិស័យកសិកម្ម និងការអភិវឌ្ឍជនបទគឺជាកត្តាជំរុញដ៏សំខាន់ក្នុងការបង្កើនប្រាក់ចំណូលប្រទេស។

នៅក្នុងឆ្នាំ២០១៨ កម្ចី ក្នុងឧស្សាហកម្មអង្ករបានកើនឡើង ៣០,១% ធៀបទៅនឹងឆ្នាំ២០១៧។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

សញ្ញាបណ្ណរបស់អាមេរិច (US bond) ធ្លាក់ចុះ ដោយសារតែភាពមិនច្បាស់លាស់នៃពាណិជ្ជកម្ម

សញ្ញាបណ្ណរបស់អាមេរិច (US bond) បានធ្លាក់ចុះកាលពីថ្ងៃអង្គារ ដោយសារតែ កិច្ចចរចាជាមួយចិនស្តីពីទំនាក់ទំនងពាណិជ្ជកម្មបានបង្ហាញសញ្ញានៃដំណោះស្រាយដែលមិនមានភាពច្បាស់លាស់។ តម្លៃរបស់បណ្ណរតនាគារដែលមានរយៈពេល ១០ ឆ្នាំ កើនឡើងជាង ២,៧% ហើយបណ្ណរតនាគារដែលមានរយៈពេល៣០ឆ្នាំ កើនឡើងជាង ៣% តម្លៃដែលអ្នកទិញទទួលបាននៅពេលលក់គឺខុសៗគ្នា ហើយបញ្ច្រាស់ទៅនឹងតម្លៃដែលទិញ) ។

កិច្ចចរចាពាណិជ្ជកម្មរវាងប្រទេសទាំងពីរកំពុងឈានដល់ដំណាក់កាលចុងក្រោយ ហើយកិច្ចប្រជុំកំពូលមួយដែលនឹងធ្វើឡើងនៅ Mar-a-Lago នាចុងខែនេះ អាចផ្តល់នូវដំណោះស្រាយដែលមានក្នុងកិច្ចពិភាក្សានាពេលនេះ។ ទោះជាយ៉ាងណាក៏ដោយ របាយ-ការណ៍ថ្មីៗនេះ បានបង្ហាញថា ការចរចាកាលពីថ្ងៃច័ន្ទនេះ មិនបានដោះស្រាយលើបញ្ហារចនាសម្ព័ន្ធនោះទេ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ការសម្រេចចិត្តអត្រាការប្រាក់ក្នុងប្រទេសជប៉ុន និងទិន្នន័យពីការវិនិយោគផ្ទាល់ពីបរទេសរបស់ប្រទេសចិន។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ ៖

ថ្ងៃចន្ទ ទី១១ ខែមីនា ២០១៩

- អត្រាអ្នកអត់ការងារធ្វើនៅម៉ាឡេស៊ី សម្រាប់ខែមករា

- ការវិនិយោគដោយផ្ទាល់ពីបរទេសរបស់ហ្វីលីពីន សម្រាប់ខែធ្នូ
- ការលក់រថយន្តរបស់ចិន សម្រាប់ខែកុម្ភៈ
- ការលក់រាយនៅឥណ្ឌូណេស៊ី សម្រាប់ខែមករា

ថ្ងៃអង្គារ ទី១២ ខែមីនា ២០១៩

- តុល្យភាពពាណិជ្ជកម្មរបស់ហ្វីលីពីន សម្រាប់ខែមករា
- ទំនុកចិត្តរបស់អតិថិជនរបស់ថៃ សម្រាប់ខែកុម្ភៈ
- ការលក់រាយក្នុងសឹង្ហបុរី សម្រាប់ខែមករា

ថ្ងៃពុធ ទី១៣ ខែមីនា ២០១៩

- អត្រាអ្នកអត់ការងារធ្វើរបស់កូរ៉េខាងត្បូងសម្រាប់ខែកុម្ភៈ
- សន្ទស្សន៍អំណាចនៃការទិញរបស់ជប៉ុន សម្រាប់ខែកុម្ភៈ
- ការបញ្ជាទិញម៉ាស៊ីនរបស់ជប៉ុន សម្រាប់ខែមករា
- ការលក់ម៉ូតូនៅក្នុងឥណ្ឌូណេស៊ី សម្រាប់ខែកុម្ភៈ

ថ្ងៃព្រហស្បតិ៍ ទី១៤ ខែមីនា ២០១៩

- ផលិតផលឧស្សាហកម្មរបស់ចិន សម្រាប់ខែមករា-កុម្ភៈ
- ការលក់រាយក្នុងប្រទេសចិន សម្រាប់ខែមករា-កុម្ភៈ
- អត្រាអ្នកអត់ការងារធ្វើនៅសឹង្ហបុរី សម្រាប់ឆមាសទី៤ ឆ្នាំ២០១៨
- ផលិតកម្មឧស្សាហកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែមករា
- ការលក់រាយរបស់ម៉ាឡេស៊ី សម្រាប់ខែមករា

ថ្ងៃសុក្រ ទី១៥ ខែមីនា ២០១៩

- ការនាំចូល និងនាំចេញរបស់កូរ៉េខាងត្បូងសម្រាប់ខែកុម្ភៈ
- តុល្យភាពពាណិជ្ជកម្ម នៅឥណ្ឌូណេស៊ី សម្រាប់ខែកុម្ភៈ
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ធនាគារជាតិជប៉ុន
- ការវិនិយោគដោយផ្ទាល់ពីបរទេសរបស់ចិនសម្រាប់ខែកុម្ភៈ